# I - ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យ ជស/រកត/០៣៩៦/១០**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស**

**ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង**

**កម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ និង អំពីរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល

**ត្រាស់បង្គាប់**

**មាត្រា ១ :** បង្កើតក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ មានឈ្មោះថាអគ្គិសនីកម្ពុជា សរសេរ កាត់ អ.ក ដែលមានភារកិច្ចផលិតបញ្ជូន និងចែកចាយថាមពល

អគ្គិសនី ទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ការប្រព្រឹត្តិទៅនឹងទំនាក់ទំនងរវាងអគ្គិសនីកម្ពុជា និងរាជរដ្ឋាភិបាលត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២ :** អគ្គិសនីកម្ពុជាជានីតិបុគ្គលមានស្វ័យភាពផ្នែកគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុមានគោលដៅពាណិជ្ជកម្ម និងមានសិទ្ធិ និងការទទួលខុសត្រូវកំណត់ដោយច្បាប់ ។ អគ្គិសនីកម្ពុជាទទួលខុសត្រូវដោយផ្ទាល់ចំពោះកំរៃ និងការបង់ខាតព្រមទាំងបំណុលទាំងអស់ត្រឹមកំរិតនៃតំលៃ ធនធានរបស់ខ្លួន ។ ក្នុងតួនាទីជាម្ចាស់នៃ អគ្គិសនីកម្ពុជា រដ្ឋទទួលខុសត្រូវក្នុងកំរិតត្រឹមបរិមាណទុនដែលរដ្ឋបានដាក់ចូលជា ភាគហ៊ុននៃដើមទុនរបស់អគ្គិសនីកម្ពុជាតែប៉ុណ្ណោះ ។

**មាត្រា ៣ :** អាជ្ញាធរអគ្គិសនីកម្ពុជា នឹងត្រូវបង្កើតដោយច្បាប់ ដើម្បីបង្កើនប្រសិទ្ធភាព ព្រមទាំងភាពបរិបូណ៌នៃសេវាអគ្គិសនីនៅកម្ពុជាតាមរយៈការជំរុញអោយមានកម្មសិទ្ធិ និងការប្រកួតប្រជែងរវាង ឯកជនក្នុងកិច្ចផលិតថាមពលអគ្គិសនី ។

**មាត្រា ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង ដោយព្រះរាជបញ្ជា

**ប្រមុខរដ្ឋស្តីទី**

ហត្ថលេខា

**ជា ស៊ីម**

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ហត្ថលេខា

**ពូ សុធីរ:**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី ១**

ព្រះហស្តលេខានិងត្រា

**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២**

ហត្ថលេខា និងត្រា

**ហ៊ុន សែន**